អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Aug-2022, 09:22
CMS/CFO: Sann Rada

# អង្គបុរេជំនុំជម្រះ
## អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ៖ ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល** ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

**ពី៖ ចៅក្រមអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

**កម្មវត្ថុ៖ ចម្លើយតបទៅនឹង "ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២" របស់អង្គជំនុំជម្រះតុលាការកំពូល**

១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានចេញ "ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២"[1] ដោយអញ្ជើញអង្គជំនុំជម្រះនានានៅក្នុងតុលាការនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត និងភាគីនានា ព្រមទាំងអង្គភាពផ្នែកគាំពារការការពារក្ដី អង្គភាពគាំពារជនរងគ្រោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្នែកគ្រប់គ្រងតុលាការ និងការិយាល័យរដ្ឋបាល ដាក់សេចក្ដីសង្កេតរបស់ខ្លួនលើ (i) គោលការណ៍ណែនាំដែលស្នើឡើង

[1] អនុស្សរណៈអន្តរការិយាល័យរបស់អង្គជំនុំជម្រះតុលាការកំពូល ការពិនិត្យឡើងវិញលើឯកសារសម្ងាត់ និងសម្ងាត់បំផុតក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ ឯកសារ F71/1/1 ("ការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល (F71/1/1)")។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និង (ii) អត្ថិភាពនៃការសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ[2]។

២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ដោយចេញដីកាដំណោះស្រាយ[3] ហើយនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានបញ្ជាក់ទៅលើដីកាដំណោះស្រាយនោះ ដោយមានការកែប្រែខ្លះៗ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[4]។

៣. អង្គបុរេជំនុំជម្រះសូមរម្លឹកទៅដល់អនុស្សរណៈអន្តរការិយាល័យរបស់ខ្លួនចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ផ្ញើជូនអង្គជំនុំជម្រះតុលាការ "ឯកសារសម្ងាត់ និងឯកសារកោសលប់ជាសាធារណៈ នៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានស្នើឲ្យចាត់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ"[5] ដែលក្នុងនោះ បន្ទាប់ពីបានពិនិត្យយ៉ាងយកចិត្តទុកដាក់រួច អង្គជំនុំជម្រះបានកំណត់ និងស្នើឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈលើសេចក្ដីសម្ងាត់ចំនួន ៩៧ និងដីកាសម្ងាត់ចំនួន ៥៤ របស់អង្គបុរេជំនុំជម្រះ សេចក្ដីសម្រេចសម្ងាត់ចំនួន ១៣៦ និងដីកាសម្ងាត់ចំនួន ២៥១ របស់សហចៅក្រមស៊ើបអង្កេត សេចក្ដី

[2] ការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល (F71/1/1) កថាខណ្ឌ ៥។

[3] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[4] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ ឯកសារ D427/2/12។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ ឯកសារ D427/2/14។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ ឯកសារ D427/2/26។

[5] អនុស្សរណៈអន្តរការិយាល័យរបស់អង្គបុរេជំនុំជម្រះ ឯកសារសម្ងាត់ និងឯកសារកោសលប់ជាសាធារណៈ នៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានស្នើឲ្យចាត់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ឯកសារ F67 ("សំណើរបស់អង្គបុរេជំនុំជម្រះសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ (F67)")។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សម្រេចកោសលប់ជាសាធារណៈចំនួន ១៧ របស់អង្គបុរេជំនុំជម្រះ និងសេចក្តីសម្រេចកោសលប់ជាសាធារណៈចំនួន ០១ និងដីកាកោសលប់ជាសាធារណៈចំនួន ០៧ របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០២ ដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈនោះ[6]។

៤. អង្គបុរេជំនុំជម្រះនៅតែរក្សាទស្សនៈរបស់ខ្លួនថា ឯកសារបច្ចុប្បន្នដែលជាឯកសារសម្ងាត់ ឬកោសលប់ជាសាធារណៈលែងមានភាពសមស្រប នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីទៀតហើយ អនុលោមតាមមាត្រា ៩.១ និង ១២.២ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ដោយមានការលើកលែងចំពោះឈ្មោះ និងព័ត៌មានផ្ទាល់ខ្លួនរបស់សាក្សី ដែលស្ថិតក្រោមវិធានការការពារ ឬដែលសំណើសុំវិធានការការពាររបស់ពួកគាត់ កំពុងរង់ចាំសេចក្តីសម្រេច គួរតែត្រូវរក្សាជាការសម្ងាត់បន្ត[7]។

---

[6] សំណើរបស់អង្គបុរេជំនុំជម្រះសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ (F67) កថាខណ្ឌ ១, ៣។ ឧបសម្ព័ន្ធនៃឯកសារសម្ងាត់ និងឯកសារកោសលប់ជាសាធារណៈ នៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានស្នើឲ្យចាត់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ឯកសារ F67.1។

[7] *សូមមើល* សំណុំរឿង ០០៤/១ (អបជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលប់ ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D309/2/1/។ សំណុំរឿង ០០៤/១ (អបជ ៥៤) សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D304/6/4។